# របាំក្រាប់

ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយវប្បធម៌អរិយធម៌រុងរឿង ទម្រង់សិល្បៈសម្បូណ៌បែប មានចម្រៀង តន្ត្រី ល្ខោន របាំប្រជាប្រិយ របាំព្រះរាជទ្រព្យនាសម័យបុរាណ គ្រប់គ្រង់និងទំនុកបម្រុងដោយព្រះមហាក្សត្រ និងរបាំប្រពៃណីនៅជាប់ជាមួយនឹងប្រជារាស្ត្រ ជាពិសេសអ្នករស់នៅតាមជនបទស្រុកស្រែចម្ការ ក្នុងតំបន់ខ្ពង់រាបនិងតំបន់ភ្នំ តាមដងទន្លេ និងសមុទ្រ។ របាំប្រពៃណីខ្មែរ មានដើមកំណើតកើតឡើងពីជំនឿសាសនា ទំនៀមទម្លាប់ ប្រពៃណី ពិធី និងការកែកម្សាន្ត។

នៅក្នុងចំណោមរបាំប្រពៃណីខ្មែរដ៏សម្បូណ៌បែបទាំងនេះ «របាំក្រាប់» អ្នកខ្លះហៅថា «របាំក្រាប»[១] ជារបាំប្រពៃណីមួយ ដែលពាក់ព័ន្ធនឹងធម្មជាតិនិងកសិកម្មស្រុកខ្មែរ ក៏ដូចជាជីវិតប្រចាំថ្ងៃនិងការកែកម្សាន្តរបស់ប្រជាពលរដ្ឋខ្មែរអ្នកស្រែចម្ការរួមមាន របាំច្រូតស្រូវ របាំគោះត្រឡោក របាំនេសាទ របាំគោះអង្រែ និងរបាំក្រាប់នេះជាដើម។

របាំក្រាប់ មានក្រឡារបាំ កាយវិការក្រមិចក្រម៉ើម កំប្លុកកំប្លែង សម្តែងឆ្លោះឆ្លងរវាងអ្នករាំប្រុសនិងស្រី និងអត្ថន័យខ្លឹមសារសាមញ្ញងាយយល់ដែលញ៉ាំងឲ្យរបាំក្រាប់មាន ប្រជាប្រិយភាពខ្លាំង ជាពិសេសនៅចុងទសវត្សទី៦០ ដើមទសវត្សទី៧០ និងក្រោយសម័យ ប្រល័យពូជសាសន៍ ប៉ុល ពត។ នាពេលបច្ចុប្បន្ន របាំក្រាប់ក៏ដូចជារបាំប្រពៃណីខ្មែរមួយចំនួនទៀតដែរ គឺគេមិនសូវបានឃើញសម្តែងឡើយ ដោយកត្តាផ្សេងៗមានបរិបទសកលភាវូបនីយកម្ម វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទំនើបដែលផ្តល់ដល់ប្រជាជននិងទស្សនិកជននូវទម្រង់កែកម្សាន្តថ្មី ទំនើប ជម្រើសសម្បូណ៌បែប និងងាយស្រួល ហើយយើងក៏មិនបានបង្កើតជាកម្មវិធីផ្សព្វផ្សាយឱ្យទូលំទូលាយផង ដែលធ្វើឱ្យ ជាពិសេសយុវវ័យមិនបានរៀនសូត្រយល់ដឹងជ្រៅជ្រះអំពីរបាំប្រពៃណីខ្មែរ ឈប់គិត និងមិនចាប់អារម្មណ៍អំពីរបាំក្រាប់និងសិល្បៈបុរាណនិងប្រពៃណីខ្មែរឯទៀតៗ។

របាំក្រាប់ កំដរដោយវង់តន្ត្រីមហោរី ដែលមានឧបករណ៍តន្ត្រី រនាត ទ្រ ក្រពើ (តខេ) ឃឹម ខ្លុយ ឈឹង និងស្គរដៃ ឬទៅតាមលទ្ធភាពនិងធនធានរបស់អ្នករៀបចំកម្មវិធី

[១] ជួន ណាត ១៩៦៧: ១០៨, ពេជ្រ សល់ ១៩៧០: ៣៥, Guesdon 1930: 214

អត្ថបទដោយៈ បណ្ឌិត សំ សំអាង

ដោយគ្មានចម្រៀងឡើយ។ ឯបទភ្លេងតែមួយបទ ដែលគេប្រើសម្រាប់កំដររបាំក្រាបនោះ គឺបទ «អណ្ដើកស៊ីត្រកួន»។ របាំក្រាប់ ជារបាំសម្រាប់ កែកម្សាន្តឬកំដរនិងញ៉ាំងបរិយាកាសឱ្យសប្បាយរីករាយក្រោយពេលច្រូតកាត់រួច ការជួបជុំគ្នា ឬនៅក្នុងកម្មវិធីសម្ដែងសិល្បៈផ្សេងៗ។

របាំប្រពៃណីខ្មែរ គឺរបាំក្រាប់ ក៏ដូចជាសិល្បៈឯទៀតដែរ គឺស្ថិតនៅក្នុងទស្សនៈ «សិល្បៈជាកញ្ចក់ឆ្លុះសង្គម» ពោលគឺលាតត្រដាងឆ្លុះបង្ហាញអំពីជីវិតរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ មានជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី ធម្មជាតិ ជីវិត និងសកម្មភាពកសិកម្មរបស់ខ្មែរ។

ដើម្បីឱ្យសិល្បៈបុរាណនិងប្រពៃណីខ្មែរ រស់រានមានជីវិតនិងលូតលាស់រុងរឿងទៅអនាគត ខ្មែរយើងត្រូវឱ្យតម្លៃ ទទួលស្គាល់ ស្រឡាញ់ ច្នៃប្រឌិត កែលម្អ លើកស្ទួយ ថែរក្សា និងផ្សព្វផ្សាយបន្ត ជាពិសេសយុវវ័យខ្មែរ ដែលជាទំពាំងស្នងឫស្សីនិងអ្នកបន្តវេន។

## ឯកសារពិគ្រោះ


ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ ទុំក្រវិល. (២០០១). *របាំខ្មែរ*. ភ្នំពេញ: អង្គការមូលនិធិតូយ៉ូតា។

ពេជ្រ សល់. (១៩៧០). *តាមលំនាំសង្ខេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Guesodn, Joseph. (1930). *Dictionnaire Cambodgien-Français*. Paris: Les Petits-Fils de Plon et Nourrit.

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1988). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





ប្រភពរូបភាព៖ The Bamboo Clappers Dance | Koulen Restaurant

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង